



« Dol- Ek »
f- le 30-12-52
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL
ប- 1 ស- 437
134

សំណាងដែលសាងបានករ　　រាសីគិនរមកពីព្រេង ។
ខ្ញុំសូមរំលឹកនឹកដល់គុណ　　មាតាបិតាខ្ញុំនេះឯង
ខ្ញុំបានបៀមបៅដោះពីក្មេង　　គុណអ្នកដាក់ស្ដែងជួយខ្ញុំផង ។
ឥឡូវនេះកូនមានទុក្ខធំ　　សត្រូវមកបំខ្ញុំជាម្ដង
សូមជួយឲ្យបានដូចបំណង　　សេចក្ដីប៉ុនប៉ងប្រាថ្នានេះ ។
សព្វារួចស្រេចស្ដេចត្រាស់ថា　　នៃពួកសេនាបើដូច្នេះ
យើងគិតសង្គ្រាមក្នុងគ្រានេះ　　កុំឲ្យវេរេះគិតឲ្យឆាប់ ។
មេទ័ពចេញពាក្យកូនទាហាន　　ការហាត់ប្រឹតប្រៀនទុកសម្រាប់
មេទ័ពថាយើងគ្រប់គ្នាស្ដាប់　　ថាបើយើងស្លាប់ក្នុងសង្គ្រាម ។
ហៅពេញស្រឡាញ់ដល់ផែនដី　　នឹងម្ចាស់សិរីស៊ីបត្តរឈាម
តាំងចិត្តតែមួយកុំទីមទាម　　នេះហើយយកឈាមក្រាលផែនដី ។
ទើបស្ដេចយាងចេញពីនគរ　　សេនាបវរប្រញាប់ខ្ញី
សេនាមាត្យហ៊ឹនមុខមន្ត្រី　　ដល់ចុងបុរីបញ្ឈប់ពល ។
ទើបឲ្យសង់ព្រះពន្លាជ័យ　　រោងរៃងរោងខ្ទំដោយខ្វាយខ្វល់
ប្រដាប់សម្រាប់ឲ្យពួកពល　　ប្រយោជន៍តទល់នឹងសត្រូវ ។
ស្ដេចទ្រង់ឲ្យលើកទង់ជ័យឡើង　　ដំកើងនៅមុខពន្លាកូវ
ឲ្យដឹងដល់ពួកខ្មាំងសត្រូវ　　ទ័ពនៅខាងនាយឃើញប្រាកដ ។
អនុសេនីយ៍ទោ-សេនីយ៍ឯក　　ឲ្យពួកទ័ពពៅស្រែកឡើងជាបទ

នគររាជដោយពាក្យហ្មត់ចត់ បួងសួងប្រាកដទេវតាថ្មី ។

## បទនគររាជ

សូមពួកទេ–ព្តា រក់–សៈមហា–ក្សត្រយើង ឲ្យបានរុងរឿង ដោយជ័យម–ង្គលស្រីសួ–ស្តី យើងខ្ញុំព្រះអង្គ សូមដេកក្រោមម្លប់-ព្រះបា–រ–មី នៃព្រះន–របតីវង្សក្ស–ត្រាដែលសាងប្រា–សាទល្អ គ្រប់គ្រងសាកេតបុរីថ្កើងថ្កាន ។ ចប់បទនគររាជតែប៉ុណ្ណោះ ។

## បទពាក្យប្រាំពីរតទៅ

ពួកទ័ពគំនាប់ដល់ទង់ជ័យ ថ្វាយព្រះពរថ្វៃមហាក្សត្រក្រេន្ត
បួងសួងទេវតានៅគ្រប់ស្ថាន សូមប្រកបមានជ័យបេស្តា ។
ស្តេចទ្រង់បង្គាប់ពួកអាឡាក់ ជានៃចូលអ្នកតែងរាជសាស្ន៍
ក្រាបទូលព្រះបាទអង្គឯកា ថាយើងអនុជាមកដល់ហើយ ។
ឲ្យប្រុងឲ្យរះប្រៀបរៀបរហ័ពល កុំឲ្យបង្អែបង្អង់ឡើយ
យើងប្រយុទ្ធគ្នាថ្ងៃនឹងហើយ យើងប្រាប់បានឲ្យដឹងសេចក្តី ។
រាជទូតនាំសាស្ន៍ថ្វាយប្រញាប់ ឯអង្គឯកាព្រះចក្រី
ស្តេចទតអស់អាថ៌សារសេចក្តី ប្រាប់រាជទូតខ្ទីឲ្យវិលវិញ ។
ក្រសត្រិយ៍ទាំងពីររៀបពលស្រេច តែមួយរំពេចឥតទុក្ខម្នេញ
គាំភ្លើងគ្រប់ដៃប្រុងប្រៀបបាញ់ ពួកពលខ្វល់ខ្វាញ់ប្រឹនះត្រៀបត្រា ។

សព្ទសូរគាំភ្លេងពួកក្រើក ស្មើនឹងរបើកព្រៃព្រឹក្សា
ញាប់ញ័រគីរីទីបព្វតា គួរឲ្យអស្ចារ្យកពផែនដី ។
ពលសេះគគោកគជា ដេញគ្នាឥតមានត្រាប្រណី
ខ្លះធ្លាក់ពីលើខ្នងដំរី ខ្លះឯបនឹងព្រៃចាំស្កាត់ពល ។
ងងឹតអ័ព្ទអស់ទាំងមេឃា ពួកពលមើលគ្នាស្ទើពុំយល់
ផ្សែងសព្វទិសាទីមណ្ឌល ស្លាប់នាយស្លាប់ពលពេញត្រៀបត្រា ។
ព្រះបាទឯកាពារាណសី ពលស្លាប់ច្រើនក្រៃពេកមហិមា
ឡើងគង់លើខ្នងអស្សពាហ៍ យកកន្សែងណាបក់ពលខ្ទី ។
ទើបកើតជាពលច្រើនអនេក គួរអស្ចារ្យប្លែកក្នុងលោកិយ
បក់ទាំងគាំភ្លេងច្រើនក្រាសក្រៃ ឲ្យកាន់គ្រប់ដៃឥតគណនា ។
គួរស្ញែងគួរខ្លាចរិទ្ធិបារមី អង្គព្រះនរបតីមានចេស្តា
ដេញពលឲ្យចូលតយុទ្ធនា ពលប្រឡូកគ្នាឥតញញើត ។
ព្រោះអាងដំរេះចេះធ្វើពល រយពាន់ហ្មឺនសែនបក់បោយកើត
ស្លាប់គរលេលកែលបក់ឡើងព្រើត កើតបានជាពលពេញដវែល ។
ព្រះបាទសាកេតអនុជា ឃើញពលយោធាគេក្រាសក្រៃល
គ្រវែងខ្សែទៅចងវណោល ពលក្រៃលដូចក្រងចងគ្រៀកនៅ ។
ជំបងកាយឯងស្លាប់គ្មានសល់ អស់ទាំងរេហ៍ពលចិត្តឃោរឃៅ
ឯអង្គព្រះបាទឯកានៅ មិនត្រូវជំបងចងពុំបាន ។

ឯកាគង់លើខ្នើងអស្សព្រាហ៍ បក់បោយយោធាឥតវិមាន
ពួកពលដែលស្លាប់ទាំងប៉ុន្មាន កើតបានគ្មានសល់ពលទាំងអស់ៗ
បាត់គ្រឿងសាស្ត្រាវុធគ្រប់ដៃ កាំភ្លើងដាវដ័យគ្មានបន្ទោះ
គ្រប់នាយកងពលពល់មិនខ្វល់ ឥតមានខ្មាំងសោះព្រោះបម្រាំងៗ
ស្ដេចឲ្យលើកពលបលទៅគ្រីក សន្ធឹកដូចព្យុះសង្រ្គាខ្លាំង
ប្រឡូកប្រឡាក់កាប់ចាក់ខ្លាំង ប្រណាំងប្រជែងដាវវែងខ្លី ៗ
ខ្លះកាប់ផ្ដាប់ពាក់កណ្ដាលខ្លួន ដួលផ្ងួនទៅផ្ទាប់ជាប់នឹងដី
ឈាមហូរចេញខ្ចាយពីកាយខ្ទី ពាសពេញផែនដីរាបមិនអស់ ៗ
ព្រះបាទឯកាពារាណសី ពលស្លាប់ច្រើនក្រៃបង់អាប់យស
ត្រាន់ព្រះហឫទ័យពលរលោះ ស្លាប់អស់ស្មើផលបរាជ័យ ៗ
ចូលចាប់ឯកាពារាណសី ដើម្បីនឹងយកមកបំណុះ
អនុសេនីយ៍ត្រីតស័ក្ដិ ១ ទូលថាកុំព្រួយបន្តិចបុះ ៗ
ព្រះបាទឯកាពារាណសីនុះ សូមព្រះទ្រង់យសទុកឲ្យខ្ញុំ
អនុសេនីយ៍ទោតីស័ក្ដិ ២ ទូលព្រះភូមីបពិត្រកុំ ៗ
ព្រួយព្រះហឫទ័យនៃបរម ទ្រង់ទុកឲ្យខ្ញុំចូលទៅចាប់
អនុសេនីយ៍ឯកប៉ៃកស័ក្ដិ ៣ ទូលព្រះបក្រីសូមទ្រង់ជ្រាប ៗ
ព្រះបាទពារាណសីអនុអត្តភាព បង់លាភខ្ញុំការអនុញ្ញារដល់
វរសេនីយ៍ត្រីតស័ក្ដិ ៤ បង្គំផ្ទាល់ខ្លួនព្រះទសពល ៗ

ទូលថាឯកាស្តេចកំហល អាងបេះបក់ពលបក្ញាំងមិនគិត ៗ
វរសេនីយ៍ទោគឺស័ក្តិ ៥ ទូលតាមបំណាំព្រះទ្រង់បុត្រ
លើកហត្ថអញ្ជលីទាំងទ្វីពិត សូមព្រះភូមិន្ទទ្រង់គិតសិន ៗ
ព្របាទឯកាពារាណសី ឡើងសោយរាជ្យថ្មីជាភូមិន្ទ
មានកន្សែងបោយទឹងនាំងឆ្អិន ជាវៀមព្រះនរិន្ទទិពសទៅ ៗ
ហេតុនេះសូមទ្រង់ព្រះសណ្តាប់ កុំចាប់ទោសខ្ញុំព្រះចៅ
សេចក្តីទូលទាស់ទោះខុសត្រូវ ពិតតាមតម្រូវតម្រាស់មក ៗ
ព្ធថាព្រះអង្គព្រាត់ព្រះវៀម បែកបាក់ទាក់ទាមត្រាប់ប្រៀតជ្រក
កង្វះព្រៃព្រឹក្សាខំរត់រក កាលទ្រង់យាងមកពីស្រុកយក្ស ៗ
អនុជាសរនាការៈស័ព្ទ ទ្រង់ព្រះសណ្តាប់តាមធុរៈ
ទឹកឃើញកាលចេញពីស្រុកយក្ស ពីរនាក់រៀមបងបែកបាត់ទៅ ៗ
ទើបស្តេចមានព្រះបន្ទូលខ្ញី វរៈសេនីយ៍ទោនោះកូរ
ថាលោកស័ក្តិ ៥ ថាបែបត្រូវ ដូច្នេះយើងនៅបង្អង់សិន ៗ
ព្រះបាទឯកាពារាណសី ដម្មោះទង់ជ័យព្រះទ័យជិន
គង់សេះបូលបមអង្គព្រះនរិន្ទ សោកេតភូមិន្ទអនុជា ៗ
បូលជិតយានចុះចាកខ្នងសេះ តម្រេះស្តេចសួរសោកសារការ
វិទ្យប្រង់ជម្បង់ភ័យឯងណា ក្សត្រាបានមកពីស្រុកអ្វី ៗ
សូមមានបន្ទូលឲ្យខ្ញុំដឹង សារស័ព្ទតម្ហឹងសព្វសេចក្តី

ចូរស្ដេចកុំលាក់នឹងខ្ញុំ ខ្ញុំមានសង្ស័យក្នុងចិត្តណាស់ ។
អនុជាសាកេតបុរីរម្យ ពួងកាសុំបញ្ជាក់ច្បាស់
សារតារអនុជាសាកេតណាស់ ចង់ច្បាស់ខ្សែបង់ដម្បងរាយ ។
អនុជាមានព្រះបន្ទូលប្រាប់ តាមដោយសារស័ព្ទពាក្យអតិប្រាយ
រឹងខ្សែបង់ដម្បងរាយ បានមកពីឆ្ងាយគឺស្រុកយក្ស ។
ព្រះបាទឯកាពារាណសី អនុជាស្ដីប្រាប់ស្ដាប់បានជាក់
ខ្សែបង់ដម្បងបានពីយក្ស ស្ដេចធ្លាក់ហឫទ័យស្ដីពុំរួច ។
ទើបដួលព្រះកាយដល់ពសុធា ហត្ថាបាទាញ័រព្រឺព្រួច
ពុជាស្រុកយក្សស្ដេចកាន់ក្ដួច គិតទៅគែគិតគូយូរហើយ ។
ឯអគ្គព្រះបាទអនុជា ឃើញព្រះជេដ្ឋាដួលកែសកើយ
ដឹងជាក់ព្រះរៀមស្ដេចច្បាស់ហើយ ទ្រង់កន្ទ្រើងសោយសោកសន្ធប់ ។
អមាត្យមន្ត្រីប័ត្រកន ក្សត្រទាំងពីរផងដោយគោរព
ទើបឱ្យដងទឹកយកមកស្រប់ ស្វាងពីសន្ធប់ដឹងព្រះកាយ ។
ព្រះបាទឯកាពារាណសី មានព្រះស្មារតីដឹងកាលណា
ប្រាកដជាក់ច្បាស់អនុជា ទ្រង់សោយសោការៀបរាប់ស្ដី ។
ប្អូនអើយៗប្អូនប្រុសវរលក្ខណ៍ ចេញពីស្រុកយក្សមកឃាតខ្ញុំ
វង្វេងបែកបាត់ប្អូនពីសី ប្រុសថ្លៃបងរកអ្នកពុំឃើញ ។
រៀមជិះសេះស្កាត់គ្រប់កន្លង ខំរកប្អូនឯងតែងអារញ្ញ

តាមដានអស្រពាហ៍ម្ដេចពុំឃើញ　　ប្រុសប្អូនអញ្ជើញទៅខាងណា ៗ
ប្អូនអើយៗប្អូនមាសអណ្ណាង　　អនុជនោមយំពង្សសង្ការ
ទិពសប្រុសព្រាត់បីឆ្នាំណា　　ទៅពេញស្នេហាបានជួបគ្នា ៗ
ប្រសិនបងដឹងបងមិនច្បាំង　　បងមិនតាំងឲ្យវេទនា
ចាំណែកអនុជទៅកនិដ្ឋា　　បើជាបកិច្ចការមិនប្រាប់បង ៗ
កាលណោះព្រះបាទអនុជា　　ស្មានសោយសោកាទូលវងស្នង
សូមទានបតិតព្រះបាទបង　　ពុំដឹងឡើយហោងអត់ទោសា ៗ
បើទូលបង្គំជាខ្ញុំដឹង　　រឿងនឹងមិនទាន់ឲ្យបែកការ
ខ្ញុំនឹងបញ្ឈប់ពលយោធា　　មិនឲ្យច្បាំងគ្នាបានឡើយនៃ ៗ
ហេតុនេះសូមទ្រង់មេត្តាប្រោស　　អភ័យឥតទោសព្រះចក្រី
សន្តោសប្រោសប្រាណក្សត្រជាថ្មី　　នរបតីខត្តិអនុជទៅ ៗ
ព្រះវរៀមម្ចាស់ប្អូនកុំយល់ថា　　ខ្ញុំតបេស្ដានឹងព្រះចៅ
បើខ្ញុំតាំងទុកជាខ្មៅ　　ព្រះចៅមានគុណធ្ងន់វិសេស ៗ
ព្រះចៅឯការពារណាស់　　ពុកអនុជស្ត្រីគ្មានប្រហែស
ព្រះទ័យស្ដេចចង់វិលប្រទេស　　និវេសបុរីរាជសេមា ៗ
អនុជអញ្ជើញព្រះវរៀមកែ　　បពិត្រចមចក្រអង្គក្សត្រា
អញ្ជើញស្ដេចយាងចូលសេមា　　សាកេតបុរីនៃយើងខ្ញុំ ៗ
ទូលព្រះបង្គំខ្ញុំអនុជ　　ឥតមានពុញចប់ព្រះបរម

យានភ្ជួនដំណើរក្សត្រិយ៍ឧត្តម ទៅដល់ក្រុងធំពារាណសី ។
ឲ្យទ្រង់ស្ដេចយានចូលសេមា បុរីរដ្ឋានៃខ្ញុំខ្ញី
ឲ្យបានប្រជាបសព្វគ្រប់សេចក្ដី ដល់ព្រះមហេសីនៃខ្ញុំផង ។
ឲ្យនាងបានស្គាល់ប្រាកដជាក់ ជាព្រះរៀមរ័កក្សត្របក្សស់ច្បង
កំសាន្តហឫទ័យលេងបានម្ដង សូមព្រះបាទបង់យានយាត្រា ។
កាលអឺយៗកាលនោះឯងនៃ ព្រះជេដ្ឋាថ្លៃពុទង្ការ
អនុជក្រាបទូលអគ្គខត្តិយា ក្សត្រាទទួលដោយមេត្រី ។
កាលនោះព្រះបាទអនុជា ត្រាស់ហៅសេនាទីនសេនីយ៍
ដង្ហែបមបក្រនរបតី ពលពាលច្រើនក្រៃពីរនគរ ។
ឯពួកសេនីយ៍នឹងសេនា ឃើញអគ្គក្សត្រាមូលសាទរ
អមាត្យរីងមានចិត្តត្រេកអរ ទាំងពីរនគរស្មើចិត្តគ្នា ។
នាំគ្នាហែស្ដេចពីរព្រះអង្គ យានចូលទៅក្នុងព្រះសេមា
លុះបានដល់វាំងទីប្រាង្គណ៍ប្រា សាទរត្ងៃថ្វាអនុជនាថ ។
កាលអឺយៗកាលនោះបវរ មូលីសុន្ទរចូលអភិវាទន៍
ព្រះរាជស្វាមីនៃនាងនាដ តាមជាតិជាក្សត្រខត្តិវង្ស ។
ព្រះអនុជាបង្គាប់ទ្ធី នៃមូលីស្រីស្រស់ពុំង៉ា
បង្គំព្រះរៀមជាជេដ្ឋា ណាស្រស់កនិដ្ឋាព្រលឹងបង ។
ព្រះនាងលើកហត្ថពីរទីឃាត អភិវាទតាមព្រះបន្ទូលស្នង

ដែលព្រះស្វាមីបង្គាប់ផង　　នាងគ្មានរំលងដល់តិចឡើយ ។
ទើបនាងមានព្រះសវនីយ៍　　ទូលព្រះរៀមថ្លៃក្សត្រត្រាណត្រើយ
ខ្ញុំត្រេកអរណាស់ម្ចាស់ម្លួនអើយ　　បានឃើញកក្រ្ពះហើយក្នុងថ្ងៃនេះ ។
ព្រះស្វាមីនៃខ្ញុំម្ចាស់　　ស្ដេចមានតម្រាស់ថាដូច្នេះ
ដំណាលប្រាប់កាលស្ដេចគង់សេះ　　ចេញចាកនិវេសបែកបាត់ដាន ។
ស្កាត់រកបមកតពគ្រប់កន្លែង　　ជលនេត្រហូរល្ហែងសព្វក្នុងស្ថាន
ណាក្មេងរលប់បាត់អស់ដាន　　ររករៀមកល្យាណពុំឃើញសោះ ។
កាលក្រោយប្រាស់ព្រាត់ពីព្រះអង្គ　　បានមកនៅក្នុងនគរស្មោះ
នឹងផ្ទះយាយតាមានសប្បុរស　　គាត់នោះជាដាយបញ្ចុះខ្សាន ។
ស្រាប់តែព្រះវរជបិតា　　ទ្រង់មានអាពាធមកបៀតបៀន
ស្ដេចទិវង្គតពីរាជស្ថាន　　ក្សត្រិក្សត្រយានទៅកាន់បរលោក ។
ក្រោយនោះសម្ដេចព្រះជននី　　រៀបធ្វើពិធីថ្វាយភ្លើងលោក
លុះយូរបន្តិចស្ដេចអន់សោក　　ទើបទ្រង់ផ្សងរកអ្នកមានបុណ្យ ។
មាតាលោកផ្សងនឹងដំរី　　បុស្សរតន៍ថ្លាថ្លៃប្រសើរលន់
អង្គព្រះអនុជថ្លៃលើជន　　ដំរីនាំមុនចូលបុរី ។
សម្ដេចមាតានឹងអមាត្យ　　ព្រាហ្មណ៍បារគូបុរោហិតខ្ញី
សម្ដេចព្រះអនុជគង់បុរី　　អភិសេកថ្មីៗនឹងខ្ញុំផង ។
មុលីសុន្ទរស្រីវរលក្ខណ៍　　នាងទូលតាមថ្នាក់ដល់រៀមបង

ព្រះបាទឯកាជ្រាបហើយហោង　ច្បាស់ច្បង់ស្រងូតស្ងួតក្រ្តា ៗ
ព្រះបាទឯកាពាភណាសី　មានបន្ទូលខ្ញីថាកន្ធ្លា
តាំងពីរមាសបងៗយាត្រា　នាំតាំងទ្វាហាទៅនគរ ៗ
ទៅលេងទឹងបង៏កំសាន្តចិត្ត　ឃើញអស់ក័យកិតហើយបវរ
ឲ្យបានសុវណ្ណស្រីអម្ពា　នាងទឹងឌុបអរជាមួយផង ៗ
កាលនោះព្រះបាទអនុជា　ប្រាប់វរជាយាមហេសីស្ងួន
តាក់តែងប្រដាប់ឲ្យឆាប់ផង　ទឹងជូនរៀមបងទៅនគរ ៗ
ទើបទ្រង់បង្គាប់ពលសេនីយ៍　ឲ្យរៀបដំរីសេះកុះករ
អមាត្យរៀបស្រេចទុកបញ្ជរ　ចាំក្សត្របវរតែងព្រះកាយ ៗ
រូបស្រេចស្ដេចគង់លើដំរី　ក្សត្រាក្សត្រិយ៍ចំនោមឆាយ
ផ្តាំអស់នាហ៊្មឺនតាំងពលទាយ　នៃអ្នកតាំងឡាយថែនគរ ៗ
ទើបស្ដេចយាងចេញចាកសាកេត　បុរីចេក្កធានថ្ងៃបវរ
សំដៅពាភណាសីនគរ　ពលពាលកុះករហែរៀបត្រាៗ
ស្ដេចយាងចូលក្នុងរាជរាំងជ័យ　ចុះពីដំរីបរអគ្គា
ទើបយាងគង់ឡើងលើប្រាង្គណ៍ប្រា　សាទរគ្នាថ្ងៃថ្វាប្រសើរក្រៃ ៗ
កាលនោះសុវណ្ណអម្ពស្រស់　រូបល្អលើសអស់ស្នំដទៃ
ចូលថ្វាយបង្គំព្រះស្វាមី　នាងត្រេកអរក្រៃឥតឧបមា ៗ
ទើបនាងមានព្រះសវនីយ៍　បពិតក្សត្រថ្ងៃខ្ពាស់ជេដ្ឋា

ខ្ញុំម្ចាស់ចង់ដឹងដំណើរណា តាំងពីទេវហាត្រូវដូចម្តេច ។
កាលនោះឯកាជាស្វាមី ព្រះមហេសីស្រស់ដូចពេជ្រ
ព្រះឪស្តាប់ប្រឹមញញឹមតេជ ត្រាស់សួរពីស្តេចតាំងទេវហា ។
ទើបស្តេចមានព្រះបន្ទូលខ្ញុំ ជានៃប្អូនស្រីដួងចិន្តា
តាំងពីក្សត្រិយ៍និងក្សត្រា ត្រូវជាកនិដ្ឋាបង្កើតបង ។
កាលអើយកាលនោះអនុជា មូលីសុន្ទរស្រស់ទួនល្អង
លើកហត្ថបង្គំក្សត្រិយ៍បង ដោយពាក្យសារសងសព្វថា ។
ក្សត្រិយ៍ក្សត្រាប្អូនព្រះអគ្គ ស្តេចគង់រហង់ដូចទេវតា
សុវណ្ណអម្ពជិតឯកា សុន្ទរជិតាជិតអនុជា ។
ដោយទ្រង់រលឹកនឹកមហេសី ឃ្លាតគ្នាយូរថ្ងៃកកចិន្តា
ទើបទ្រង់ឲ្យរៀបគ្រែសយនា ថ្វាយអនុជានិងសុន្ទរ ។
ប្រាសាទដទៃដាច់ពីគ្នា ទ្រង់នាំជាយាស្រសបវរ
ព្រះអនុជានឹងសុន្ទរ សុវណ្ណអម្ពនឹងឯកា ។
ទ្រង់យាងចូលផ្ទំដោយសុខសាន្ត សម្រាកសម្រាន្តព្រះកាយា
តាំងពីរនាងនឹកព្រះកស្តា តម្រេកតណ្ហាឥតឧបម័យ ។
លុះព្រឹកក្តីស្វាងបំព្រាងព្រះ សុរិយារៀងរះឧណោទ័យ
តាំងប្អូនក្សត្រាតើនបាកស័យ បេញកង់រពង់ជ័យមន្ត្រីគាល់ ។
ទើបស្តេចជំនុំនឹងមន្ត្រី ដោយព្រះហឫទ័យទ្រង់ពីធល

នឹងព្រះអនុជានិមល        មហេសីសោកសល់ទាំងពីរផង ។
ព្រះបាទឯកាថាប្អូនអើយ        ចំណែកមាតាបិតាបង
ប្រាស់ឃ្លាតយូរណាស់មកហើយហោង        ម៉្លេះសំនឹកបងនឹងអនុជ ។
មហេសីទាំងពីរលើកហត្ថា        ក្រាបទូលក្សត្រាឥតមានទប់
ដល់ព្រះវររៀមថ្លៃនឹងអនុជ        ឥតមានបន្ទប់ព្រះហឫទ័យ ។
ទើបនាងទូលថាបើដូច្នោះ        សូមព្រះទ្រង់យសប្រាប់សេចក្ដី
យាងទាំងព្រះអង្គខ្ញុំមហេសី        នឹងអនុជថ្លៃទាំងពីរប្រាណ ។
ពួកពលទាំងពីរព្រះនគរ        ច្រើនក្រៃក្រុះករពន់ប្រមាណ
ដង្ហែចេញពីព្រះរាជស្ថាន        នឹងបានទៅដល់ព្រះមាតា ។
ព្រះបិតានៅឯស្រុកនាយ        លោកបានរីករាយព្រះចិន្ដា
ព្រោះស្បិតបានឃើញរាជបុត្រា        ដែលព្រាត់ឃ្លាតឃ្លាមកយូរហើយ ។
កាលនោះព្រះបាទអគ្គឯកា        ព្រះរាជាទូលថ្លាប់ឆ្លើយ
ថាពាក្យប្អូនស្រីស្ដីត្រូវហើយ        ប្អូនអើយកំណត់បីខែទៀត ។
ទើបទៅអញ្ជើញព្រះជននី        ជនកទាំងពីរកុំឲ្យឃ្លាត
នៃអស់មន្ត្រីនឹងអមាត្យ        តែបីខែទៀតយើងនឹងទៅ ។
តែថាឥឡូវបងសូមប្រាប់        សេចក្ដីសារស័ព្ទឲ្យប្អូនពៅ
ទាំងបីអង្គប្រាណបានជ្រាបនូវ        សេចក្ដីខុសត្រូវជួយពិគ្រោះ ។
កាលបងទៅនៅនឹងស្រុកយក្ស        បានផ្ដាំជាក់លក្ខណ៍នឹងបងស្មោះ

គ្រប់ប្រាំមួយឆ្នាំវិលវិញចុះ　　យក្សនោះប្រាប់ថាកុំឲ្យខាន ៗ
សូមបើងជាកូនទាំងពីរនាក់　　ឲ្យទ្រព្យទាំងបួនប្រការបាន
យើងជាកូនធម៌យក្សកល្យាណ　　ដូចនេះត្រូវខានប្ដូរត្រូវទៅ ៗ
ហេតុនេះត្រូវប្អូនជួយពិគ្រោះ　　ពាក្យនោះប្រគល់ឲ្យស្រីពៅ
ទាំងពីរនាងឆ្លើយមកតោមឆ្ពៅ　　ឲ្យទៅប្ដូរនៅនាងប្រាប់បង ៗ

សុវណ្ណអម្ពទឹងមូលី-　　សុន្ទរនារីនាងឆ្លើយស្នង
ស្ដេចយក្សមានគុណក្រៃគន្ទង់　　សូមព្រះបាទបងយាងកុំខាន ៗ
ក្រែងយក្សមានការកិច្ចអ្វី ៗ　　នឹងព្រះបក្រិក្យត្រូកល្យាណ
បានជាទ្រង់ផ្ដាំកុំឲ្យខាន　　ប្រាំមួយឆ្នាំបានឲ្យវិលវិញ ៗ
នាងខ្ញុំទាំងពីរពុំដឹងកិច្ច　　ជាការស្ដេច ៗ កុំតោម្ចេញ
តែថាព្រះអង្គឆាប់វិលវិញ　　នឹងយាងទៅតាមព្រះមាតា ៗ
បិតានៅស្រុកឯនាយនៃ　　ឆ្ងាយពន់ពេកក្រៃក្នុងព្រឹក្ស
ម៉្លេះសំមើលផ្លូវដល់បុត្រា　　ឆាប់វិលវិញណាព្រះបាទបង ៗ
កាលនោះព្រះបាទអនុជា　　ហៅអស់សេនាមន្ត្រីផង
ឲ្យហែក្សត្រីយ៍ស្ងួនល្អង　　វិលបុរីផ្គងកងសេនា ៗ
កាលអង្គក្សត្រាទាំងពីរប្រាណ　　លាមហៃសីបានស្រេចកាលណា
ចេញចាកពីក្រុងព្រះភារា　　សំដៅសេមានគរយក្ស ៗ
រឿងនេះឈប់សុះមិនចរចា　　សូមថ្លែងពណ៌នាទៅតាមថ្នាក់

ស្រដីតំណាលពីស្រុកយក្ស　　កើតមានបំពាក់ពាក់ចងគ្នា ។
កាលពីយកាលនោះក្រុងអសុរី　　មានល្បីឮពាសពេញសេមា
ក្រុងយក្សជាទៃខ្លាចគ្រប់គ្នា　　អសុរីក្រុងមារឈ្មោះមហាមេឃ ។
ស្តេចមានឯកអគ្គមហាមហេសី　　សុវណ្ណកេសីល្អបំផ្លែក
ទើបក្រុងអសុរាលើកជាឯក　　ល្អថ្លៃកលើសអស់ស្ត្រីទាំងឡាយ ។
មានបុត្រាមួយឈ្មោះមហាតាល　　ជាបុត្រិ៍ត្រកាលពេះសិល្បសាយ
ពេះទាំងសណ្ដាំពេះទាំងស្រាយ　　ពេះទាំងថ្ងៃកាយពេះនិម្មិត ។
ពេះល្បីសីល្បសាស្ត្រលើសអស់យក្ស　　គ្មានទើសគ្មានទាក់អំពីរទ្ធិ
រៀនពីឥសូរពូកែពិត　　ក៏ធ្វើឲ្យល្បិតបានទាំងអស់ ។
ថ្ងៃពីមហាមេឃជាបិតា　　ត្រង់រាជសេមានៅក្នុងកោះ
កណ្ដាលសមុទ្រកុំទាំងអស់　　ឈ្មោះកោះគីរីរាជបុរី ។
យក្សមានពលរេហ៍សេនាច្រើន　　រាប់រយពាន់ហ្មឺនបុទ្ធក្រៃ
នៅក្នុងក្រុងអសុរី　　មានល្បីរន្ទឺសព្វស្ថាន ។
រឿងនេះខ្ញុំស្ទះដោយទំនង　　តំណើរដើមទងតាមដោយដាន
ក្រុងពេជ្របុរីព្រះរាជស្ថាន　　ក្សេមក្សាន្តឥតមានទុក្ខភ័យា ។
យក្សវិរុឡ្ហមាត្យនឹងមហេសី　　នាមវក្សត្រិយ៍ស្រីចន្ទ្រា
បុត្រីស្រីចន្ទបទុមា　　ល្បីល្អស្មារក្រុងបុរី ។
ព្រះជន្មបានជប់ប្រាំមួយឆ្នាំ　　ស្រស់ឆាំស្រស់ឆើតក្រព្រឹមប្រិយ៍

ទ្រលុកទ្រលន់សាច់ទន់ខ្ចី កេសីរលង់ទ្រង់រលើប ៗ
សាច់សល្អស្អាតហ្មត់ផ្ទូរផង់ ត្រចះត្រចង់គួរឲ្យស្រើប
មើលថ្ពាល់ទាំងពីរគួរបង់ជើប ចំពើបចំពាក់ចិត្តគ្រប់គ្នា ៗ
នេះពេញហៅល្អក្នុងបុរី ឮល្បីខ្ទរទៅគ្រប់ទិសា
តម្ណឹងដល់ក្រុងអសុរា នគរនាមថាកោះគីរី ៗ
កាលនោះមហាមេឃក្រុងអសុរី ផ្ដាំអគ្គមហេសីថាទេពី
ថាវៃនេះឆោមស្រស់អស់នារី បង់ចេញទៅទីពេជ្របុរី ៗ
តម្ណឹងថាបន្ទូនបទុមា បុត្រីអសុរាល្អលើសស្រី
បើឃើញត្រូវចិត្តបង់គិតស្ដី ត្រឡប់វិលវៃរៀបកស្ការ ៗ
ដូចនេះនាងនៅចាំវាំងជ័យ មើលអស់សេនីយ៍ស្រីស្រិង្គារ
លាស្រេចស្ដេចចាប់ដម្បងថ្វា ពេជ្រហោះវេហាស៍សំដៅទៅ ៗ
រំលងសមុទ្រគីរីព្រៃ លើអាកាសស័យខ្ពស់សន្ធៅ
យក្សហោះលឿនលន់ពន់ពេកក្រៃ លុះបានដល់ទៅពេជ្របុរី ៗ
ទើបក្រុងអសុរីចរចុះផ្គង ដល់ស្រេចហើយហោងលើផែនដី
ហត្ថកាន់ដម្បងចូលឃ្លាតខ្ចី មហាមេឃអសុរីដល់ខ្លោងទ្វារ ៗ
ដល់ហើយសូមចូលក្នុងរាជវាំង យក្សយាមថាចាំទូលរាជា
ព្រះនាមអ្វីទៅនៅស្រុកណា ឲ្យក្រុងអសុរាស្ដេចទ្រង់ជ្រាប ៗ
ឯយើងនេះឈ្មោះក្រុងមហាមេឃ បុរីឯកកោះគីរីរាប

ទៅទូលក្សត្រាឲ្យបានជ្រាប    តាមដោយសភាពសព្វសេចក្ដី ៗ
អមាត្យយាមទ្វារចូលសំដៅ    អង្គព្រះបរមពៅពេជ្របុរី
ទូលថាបពិត្រព្រះនរបតី    មានក្រុងអសុរីចូលសូមជួប ៗ
អមាត្យក្រាបទូលតាមដំណើរ    ទើបក្សត្រប្រសើរទ្រង់រួមរួប
ឲ្យចូលមកចុះបើចង់ជួប    សម្រួមសម្រួបពីការអ្វី ៗ
អមាត្យយក្សថ្វាយបង្គំលា    មកដល់ខ្លោងទ្វាររំពេចខ្ញី
ប្រាប់ដល់មហាមេឃអសុរី    បរបូលតាប់វៃដល់ក្សត្រា ៗ
កាលនោះវិរុឡ្ហាមាត្យក្រុងអសុរី    ស្ទុះមកចាប់ដៃមហាមេឃណា
ថាយីក្មេងឯងមកមានការ    ប្រាថ្នាអ្វីណាប្រាប់យើងផង ៗ
មហាមេឃឆ្លើយប្រាប់ថាក្មើអើយ    យើងមកនេះហើយមានបំណង
ប្រាថ្នាចង់ធ្វើជាតន្វី    ល្បីបុត្រីស្ងួនដល់ទៅខ្ញុំ ៗ
ថាល្អឥតមានទាស់ត្រង់ណា    ចង់ឃើញធីតាបន្ទន់បទុម
ដូចនេះក្មើអើយយើងសូមសុំ    មើលកូនក្រមុំក្មើបាឧម្តង ៗ
ក្រុងវិរុឡ្ហាមាត្យអង្គអសុរី    ពួមហាមេឃស្ដីថាបំណង
នឹងគិតចង់ធ្វើជាតន្វី    វិរុឡ្ហាមាត្យឆ្លើយឆ្លងថាក្មើអើយ ៗ
ចង់មើលបានដែរតែកូននេះ    បំពាក់ទាក់ទិននឹងគេហើយ
ការនេះមិនកើតទេក្មើអើយ    បើខ្ញុំព្រមឲ្យមានរឿងធំ ៗ
ពីព្រោះកូននេះឲ្យទៅគេ    តាំងពីអាយុនៅដប់ឆ្នាំ

សព្វថ្ងៃខ្ញុំនៅតែរង់ចាំ　　គ្រប់ប្រាំមួយឆ្នាំៗនឹងហើយ ៗ
វិរុឡ្ហាមាត្យប្រាប់សព្វគ្រប់　　មហាមេឃអសុរីថាក្មួយអើយ
បើច្នោះនាំនាងចេញមកហើយ　　ចំណាប់យើងកាត់មកពីឆ្ងាយ ៗ
ចង់ឃើញឲ្យជាក់ច្បាស់នឹងភ្នែក　　ល្បីល្អចម្លែកលើសស្រុកឆាយ
ជាមែនឬទេគេអធិប្បាយ　　តាមពាក្យខ្ចរខ្ចាយថាល្អណាស់ ៗ
ក្រុងវិរុឡ្ហាមាត្យរង្គអសុរី　　ហៅព្រះមហាសីស្រីឆោមឆាយ
នៃវរចន្ទ្រាស្រស់កបកាយ　　ដើតឆាយហៅចន្ទ៍បទុមា ៗ
បុត្រីនៃយើងឲ្យមកអាយ　　ផុតពុកឲ្យហៅមកមានការ
ឲ្យនាងចូលមកឆាប់ៗពា៎　　កុំស្រស់ពីតាបផ្អង់ឡើយ ៗ
កាលនោះក្សត្រិយ៍ស្រីចន្ទ្រា　　ពុស្សាមីណាប្រើនាងហើយ
ទើបមានសវនីយ៍ស្តីធ្ងន់ធ្ងើយ　　ប្រាប់កំលៀនឲ្យហៅប្រញាប់ ៗ
កំលៀនដើរដល់ប្រាង្គណ៍ប្រាសាទ　　ស្រីស្រស់ឆោមស្អាតទូលប្រញាប់
បពិតក្សត្រិយ៍សូមសណ្តាប់　　បីតាបង្គាប់ឲ្យព្រះនាង ៗ
យាងទៅដំណាក់ព្រះបិតា　　ឲ្យឆាប់រួសរ៉ាតាមសូរសៀង
ទ្រង់ស្តេចមានការដល់ព្រះនាង　　ឲ្យយាងប្រញាប់ឆាប់កុំខាន ៗ
ទើបនាងទ្រង់តែងព្រះកាយា　　ប្រហែលកញ្ញាក្នុងសួគ៌ស្ថាន
ចុះចាកពីប្រាង្គណ៍ស្រីកល្យាណ　　កំលៀនពីរប្រាណដង្ហែមក ៗ
ចន្ទ៍បទុមាស្រស់ពន្លឹក　　ពន្លឺដូចទឹកដែលរលក

សម្បូណ៌រលង់ដូចគេយក មកខាត់រលីងទៀងរលោង ៗ
សុគន់ទាំងគូរដូចបទុម រៀបរីកក្រពុំទ្រង់សម្ពោង
ត្រសុំត្រសូលកន្ត្រាឈ្នង បំព្រងញញឹមខឹមជិតស្លា ៗ
ស្រលួតស្រឡះសាច់ហ្នួតសូន្យ មើលមិនឆ្អែតចិត្តជាប់ចិន្តា
ល្អនេះហៅល្អគស់រូបា ល្អគ្មានស្រីណាមកផ្ទឹមបាន ៗ
ខានយានមកដល់ព្រះបិតា មាតាក្សត្រីយ៍ស្រីកល្យាណ
លើកហត្ថទាំងទ្វីអញ្ជលីថ្កាន បង្គំក្សត្រកាន្តទាំងទ្វេហា ៗ
នាងមានសេទើយ៍ថាបពិត បិតាទ្រង់រទ្ធមានកិច្ចការ
ថាឲ្យខ្ញុំមកឆាប់រួសរាំ តើព្រះបិតាមានការអ្វី ៗ
វិរុឡ្ហមាត្យអសុរជាបិតា បុត្រីទូលថាសព្វសេចក្តី
ទើបស្តេចឆ្លើយថានៃកូនស្រី មហាមេឃអសុរីចង់ឃើញកូន ៗ
កាលនោះមហាមេឃអសុរីយក្ស ឃើញហើយស្នេហ៍ធ្លាក់ថ្លើមបាត់សូន្យ
ដូចគេកន្ត្រាក់ញ័រកស់ខ្លួន ស្មារតីឈឹងសូន្យពុំដឹងប្រាណ ៗ
ភាំងមើលក្សត្រីយ៍ស្រីវលក្ខណ៍ ដោយមានចិត្តស្ម័គ្រទឹងកល្យាណ
សំទឹងកូនប្រុសស្រស់កុំផាន បើបានជាគូរម្យស្នា ៗ
ម៉្លេះសំពេញចិត្តស្នេហ៍មេត្រី សុវណ្ណគេសីមហេសីណា
ម៉្លេះសំពេញចិត្តរាជបុត្រា មហាតាលអសុរាជាកូនប្រុស ៗ
មហាមេឃអសុរីស្តីទៅថា ទីងវិរុឡ្ហមាត្យបើដូចនោះ

ក្អើអើយកូននេះទុកឲ្យប៉ុះ ទោះបីត្រូវខុសស្រេចលើខ្ញុំ ៗ
វិរុទ្ធមាត្យថាមិនបានទេ គ្មានកូនទំនេរក្អើកុំ ៗ
បើខំបរះបេសកើតរឿងធំ ក្អើអើយអ្នកកុំគិតដូច្នេះ ៗ
កូនស្រីឲ្យមានប្ដីរួចហើយ ក្អើរុយខ្ញុំមិនបេះគេបេះ
ធ្វើពាក្យសច្ចៈកុំឲ្យទេះ ទោះស្ដេចទោះរាស្ត្រពោលទៀនត្រង់ៗ
មហាមេឃពោលថានែក្អើរុយ ពាក្យថាបេះហើយមិនល្ហះបង់
ធម្មតាប្រាជ្ញមិនល្ហះល្ងង់ ធម្មជាតិអ្នកត្រង់មិនឈ្នះពាល ៗ
ធម្មជាតិខានកើតមិនឈ្នះស្លាប់ ច្បាប់ថាឯកិច្ចមិនឈ្នះកល
យើងធ្វើក្មៀមៗគោរយកផល ខ្ទះអ្វីកិច្ចកលយើងធ្វើកើត ៗ
ខយើងសន្យាប្រាំមួយឆ្នាំ ឥឡូវយើងចាំឥតកើនកើត
ហួសប្រាំមួយឆ្នាំយើងកែកើត ក្អើរុយបំផើតបំផុតកល ៗ
មហាមេឃអស្សុភគិតខែឆ្នាំ រាប់តាមចំណាំដប់ខែសល់
លើសប្រាំមួយឆ្នាំដោយកិច្ចកល ក្អើរុយចាំដល់ណាទៅទៀត ៗ
បើបេះខ្ញុំលទៅបុរី គិតបួលមកស្ដីដោយធ្ងុះធៀត
ខ្ញុំស្ដីប្រែហើយគិតការទៀត ត្រង់ការរំពេទស្រេចលើខ្ញុំ ៗ
មហាមេឃអស្សុភលាវិលវឹង ហៀវហោះចេញគឹងបុរីរម្យ
រំលងសមុទ្រភលត្រៃកុំ ដល់បុរីធំកោះគីរី ៗ
យក្សប្រប្រុះផ្គងចូលកំណ័រ ត្រាស់ហៅមហាសីលាទេពី

នឹងបុត្រាមកជុំទាំងទ្វី នៃអ្នកទាំងពីរចូលចាំស្តាប់ ៗ
ដំណាលពីចន្ទន៍បទុមា ស្រីក្នុងលោកាគ្មានតម្រាប់
នឹងយកមកប្រៀបប្រដូចប្រាប់ ស្រីស្រស់ចំណាប់ឥតផ្ទឹមបាន ៗ
ពេញហៅថាល្អសព្វអស់អង្គ ត្រចះត្រចង់ស្រីកល្យាណ
ពន្លឺភ្លឺដូចកែវសុរិកាន បើបានរួមប្រាណនឹងកូនយើង ៗ
សមផាមហេសីស្តេចសោយរាជ្យ សមមានអំណាចឫក្សក្រុំថ្កើង
សមនឹងសក្តិយសនគរយើង នឹងបានរុងរឿងថ្កើងតទៅ ៗ
ទើបវាត់ឲ្យរៀបបណ្ណាការ អ្នកផ្ទូរទៅមហាបូលថែបូរ
តណ្តឹងតាមច្បាប់ពីម៉ែឪ ផ្ញើតាមតម្រូវតម្រាយចាស់ ៗ
មានគ្រប់ប្រដាប់កស្តការផង ច្រើនក្រៃកន្ទុងពន់ពេកណាស់
ជ្រូកក្តាន់មាន់ទាខ្វៃពុះវះ ច្រើនណាស់រាប់រយគ្រប់ៗមុខ ៗ
ចំណែកផ្លែឈើមានសព្វគ្រប់ ចេកដូងខ្នុរស្វាយរៀបដាក់ទុក
ចំណែកខាងនំរៀបដាក់ស្មុក មានគ្រប់ ៗ មុខគ្មានខ្វះអ្វី ៗ
ទើបស្តេចឲ្យរៀបពលយោធា ទាហានសេនាមុខមន្ត្រី
កាំភ្លើងតូចធំដាវវែងខ្លី ចេញចាកបុរីកោះគិរី ៗ
ហោះឆ្លងសមុទ្រវាលព្រៃធំ ដង្ហោលដង្គុំទៅមេឃមីរ
សុទ្ធតែពួកយក្សញាក់ប្រថពី ញ័រទាំងគិរីព្រៃព្រឹក្សា ៗ
លុះដល់ក្រុងពេជ្របុរីរម្យ យក្សចរចុះជុំពេញត្រៀបត្រា ៗ

ស្តេចឲ្យសង់ពេនព្រះពន្លា ទទួលយោធាដាន់ដប់ហ្មឺន ៗ
ទើបក្រុងមហាមេឃទ្រង់ត្រាស់ថា ឲ្យរៀបកស្ការថាយ៉ាងច្រើន
របស់ណាតិចដាក់បន្ថើន រៀបឲ្យច្រើនៗសមនឹងគុ: ៗ
នំដាក់ដោយនំម្ហូបដោយម្ហូប ចំណែកផ្លែឈើដាក់គ្រប់មុខ
មុខណាដាក់ដល់គ្រប់រយគុ: សឹងមានគ្រប់មុខមិនឲ្យខ្វះ ៗ
មហាមេឃអសុរឲ្យលើកឡើង លើប្រាសាទថ្មើងថ្កានត្រចះ
គាន់គ្រឿងកស្ការនាប់រូតរះ តាមព្រះបន្ទូលក្រុងយក្សា ៗ
មហាមេឃអសុរនាំមហេសី នឹងបុត្រាខ្ទីអគ្គវរមហា
នឹងពួកសេនីយ៍ស្រីស្រីសង្គា ឡើងគាល់អសុរវិរុឡ្ហមាត្យ ៗ
ដល់ហើយអង្គុយនៅត្រៀបត្រា លើទីប្រាង្គណ៍ប្រាប្រៃសីរស្អាត
មហាមេឃឲ្យកូនក្រាបអភិវាទ ដល់ក្រុងវិរុឡ្ហមាត្យជាបិតា ៗ
ហើយឲ្យសំពះមាតាក្មេក ស្រីស្រស់ចម្លែកវរបុត្រា
ហើយឲ្យសំពះយក្សរាមា ដែលជាមេបាក្មេកនោះ ៗ
ហើយទើបមេបាយក្សប៉ុន្មាន អង្គុយរៀបប្រាណតាំងស្រីប្រុស
លើប្រាង្គណ៍ប្រាសាទច្រើនប្រូងប្រុះ តាំងពួកខាងប្រុសក៏ច្រើនណាស់ ៗ
ហើយទើបអគ្គវរនឹងចៅមហា ថ្លែងពោលវាចាដោយរអាស
ថាខ្ញុំមកពីស្រុកឆ្ងាយណាស់ ប្រាថ្នាស្នេហ៍ស្រះបួលមកដល់ ៗ
សូមទានមេបាតាំងប៉ុន្មាន អង្គុយរៀនប្រាណកុំទើងថ្កល់

យើងខ្ញុំប៉ុន្មានបានមកគាល់ សូមទានបង្គំលាកូនស្រីលោកៗ
ដើម្បីតណ្ហាំងថ្វាយបុត្រា ក្រុងអសុរស្ដេចមានជោគ
ផ្សំផ្គុំនឹងកូនរបស់លោក ឲ្យសោយរាជ្យគ្រងរដ្ឋបុរី ៗ
កាលនោះវិរុឡ្ហាមាត្យវរចន្ទ្រា ឲ្យហៅធិតាស្រស់ប្រិមប្រិយ៍
តែងគ្រឿងប្រដាប់ឆាប់ៗខ្ចី អម្ពរស្រស់ខ្ចីស្រីឆោមឆាយ ៗ
ប្រៃហែលដូចជាកូនទេវតា ចុះពីសួគ៌ាមកនៅអាយ
ទ្រង់គ្រឿងប្រដាប់សម្រាប់កាយ អលង្ការទាំងឡាយល្អឥតផ្ទឹម ៗ
ថ្ងៃពីចិត្តនាងចន្ទន៍បទុម ទ្រង់ទឹកប្រាម្ភក្លាចសង្រ្ហម
លន្ទង់លន្ទោចន្លាយលន្ទឹម ទទឹមទទឹងព្រះស្វាមី ៗ
ធុះធុព្រះបង្គអស់បានយល់ ប្អូនកើតទុក្ខទល់ពាល់ពាត្រិ
ម្ដេចបាត់សូន្យឈឹងដូច្នេះនៃ ឲ្យប្អូនមមៃពល់វេលា ៗ
នាងតែងខ្លួនស្រេចបវរប្រុះផ្គង គីលៀងពីរធងហៃធីតា
សំដៅប្រាសាទព្រះបិតា ដល់ស្រេចហើយណាវន្ទាខ្ចី ៗ
ពួកយក្សអង្គុយនៅត្រៀបត្រា ឃើញនាងធីតាវរក្សត្រិយ៍
ត្រចង់ត្រចះដូចទេពស្រី យក្សលាន់មាត់ស្ដីថាយីអើ ៗ
នេះពេញហៅល្អក្នុងបុរី ឥតមានស្រីណាប្រដូចស្មើ
ល្អអីហៅល្អស្រស់ប្រសើរ គួរឲ្យចង់មើលមិនដាក់ភ្នែក ៗ
ថ្ងៃពីឯកអង្គអសុរបុត្រ ឃើញនាងប្រាកដបទយល់ថ្លែក

ឃើញហើយមើលសឹងមិនដាក់ភ្នែក　　ល្អនេះល្អឯកចម្លែកស្រី ។
គិតថាម្ល៉េះហើយយកឲ្យបាន　　ទុកក្នុងទីស្ថានរួមបេតី
ដម្កុំដម្កើងឡើងលើសស្រី　　គួរឲ្យមេត្រីក្តីស្នេហា ។
កាលនោះនាងចន្ទ៌បទុមស្រី　　ឃើញបុត្រអសុរីនាងខ្លាចផ្សា
នឹកដល់ពលឯកអង្គបក្កព　　ដែលជាស្វាមីប្តីនាងមុន ។
នាងថ្វាយបង្គំព្រះបិតា　　ក្រោកចាកអាស្នាកាយទោរទន់
នឹកព្រះស្វាមីស្រីពេកពន់　　ទឹកភ្នែកដោរដន់ហូរដល់ដី ។
កំលៀងទាំងពីរដៃផ្ហូនៅ　　នាំនាងស្រីពៅចរចេញខ្ញី
ឡើងលើប្រាសាទរាក្សត្រិយ៍　　នាងឥតស្តីរកស្ត្រីណាឡើយ ។
នាងយាងឡើងលើគ្រែសុវណ្ណា　　បិទបាំងសន្ធិយាជិតជុំហើយ
ព្រះនាងទ្រង់គេងនៅលើខ្នើយ　　ទឹកភ្នែកឥតស្បើយដោកកក្តា ។
ទង្គិះក្បែកក្បាលអួលចុកណែន　　ទុក្ខនេះហៅសែនតឹងនុក
តឹងអីយតឹងម្ល៉េះមិនបេះថា　　ឥតមាននរណាជួយខ្ញុំផង ។
ឱឱស្វាមីប្តីស្នេហា　　លែងឃើញកញ្ញាប្អូនហើយហោង
ពេលនេះប្អូនខ្ស័យចោលព្រះបង　　ម្តេចប្រុសស្នេហ៍ស្នងមិនមកនាថ ។
សោកហើយសែនសោកបោកអង្គប្រាណ ខ្លួនអើយម្តេចបានស្លាប់ប្រញាប់
កោតចិត្តព្រះបងមិនមកឆាប់　　ឲ្យទាន់ប្អូនស្លាប់បានឃើញមុខៗ
ឥឡូវគេមកគិតរៀបការ　　នឹងប្អូនហើយណាយកទៅស្រុក

ក្តៅអើយសែនក្តៅសៅវិតក្ក　អស់បានឃើញមុខបងទៀតហើយ ។
គូអើយគូព្រេងវេងព្រាត់　ប្រាស់ចោលប្អូនបាត់មិនមកឡើយ
ឥឡូវគូកម្មមកដល់ហើយ　ព្រេងអើយធ្វើម្តេចបានជួបគ្នា ។
នាងលើកដៃឡើងផ្សងព្រះឥន្ទ្រ　កោសិន្ទ្រនៅក្នុងស្ថានសួគ៌ា
សូមឲ្យលោកជួយខ្ញុំផងណា　ខ្ញុំមានទុក្ខាទឹកស្វាមី ។
នាងសោកអស់មួយរាត្រីយប់　តាំងពីព្រលប់ដល់រស្មី
សុរិយារៀងរះខណ្ណាល័យ　ក្សត្រិយ៍នាងផ្ទុំពុំក្រោកឡើយ ។
លុះដល់ពេលព្រឹកម៉ោងប្រាំបី　អ្នកផ្ទរចៅមហាឡើងមកហើយ
ឲ្យនាំកូនស្រីមកផ្ទឹមខ្នើយ　ស្រេចហើយបងដៃទឹងសំពះ ។
អ្នកផ្ទរជំរាបទៅមេបា　ព្រមទាំងអ្នកមហាសូមប្រសាស្ន៍
ឲ្យនាំកូនស្រីឆាប់រហាស់　ដល់ពេលសំពះជិតណាស់ហើយ ។
ឯក្រុងអសុរាពេជ្របុរី　បើកីលៀងខ្ញុំថានាងអើយ
ទៅហៅបុត្រីស្រីស្រស់ហើយ　ត្បិតបិតាឲ្យមកប្រញាប់ ។
គីលៀងផ្ទៀងស្តាប់ត្រើនុក្ករ　ទៅដល់ពីតាដូចបង្គាប់
បពិត្រព្រះនាងយាងឲ្យឆាប់　ប្រញាប់ឲ្យទាន់ព្រះបន្ទូល ។
ព្រះនាងទ្រង់គ្រឿងអលង្ការ　រួចស្រេចកាលណានាងយាងចូល
រួសរាន់ឲ្យទាន់ព្រះបន្ទូល　ចរចូលទៅជិតព្រះបិតា ។
ព្រះនាងទៀងទូលថាបពិត្រ　សូមទានទ្រង់បុទ្ធព្រះបេស្តា

បង្គាប់ឲ្យខ្ញុំមកមានការ      យ៉ាងណាសូមទ្រង់មេត្តាប្រោស ។
អសុរាបិតាថាកូនស្រី      ត្បិតអីបីតាគិតសន្តោស
នាងតាមឪពុកកុំឲ្យទោស      ចូលនាងសន្តោសសេចក្ដីមើល ។
បិតាប្រកែកថាមិនឲ្យ      គេបេះតែបូលយកងងើល
កូនស្រីកុំថាបិតាព្រើល      ងងើលងងិតគិតមិនយល់ ។
ឥឡូវគេបោះបូកបំណាំ      ហួសប្រាំមួយឆ្នាំកូនទិមិល
លើសដប់ខែហើយមិនឃើញដល់      តើស្រស់ទិមិលជាដូចម្ដេច ។
ចន្ទ៌បទុមស្រីនាងទូលថា      ដល់ព្រះបិតាមួយរំពេច
ដោយពាក្យសច្ចៈគ្មានកលកិច្ច      ទើបនាងសម្រេចដល់បិតា ។
សូមទានឥតទោសលោកឪពុក      ដែលលោកដាក់ទុកកូនឯណា
លើកឲ្យទៅក្រុងអសុរា      ប្រុងរៀបចំការក្នុងថ្ងៃនឹង ។
កូនសូមដំរាបឲ្យបានជាក់      ជ្រាបដល់ក្រុងយក្សជាតំណឹង
ការអ្នកឯណាខ្ញុំចង់ដឹង      ដែលប្រឹងចូលមកប្រិនត្រៀបត្រា ។
បំណែកខាងខ្ញុំជាកូនស្រី      ទ្រង់ឲ្យមានប្ដីយូរហើយណា
កូនណាមួយទៀតដែលរៀបការ      សូមព្រះបិតាប្រាប់កូនផង ។
កាលនោះអសុរីជាបិតា      ចន្ទ៌បទុមាសួរប្អោះហោង
រកពាក្យត្រង់ណានឹងឆ្លើយឆ្លង      តនឹងនាងផងបាត់សូន្យឈឹង ។
បំណែកអ្នកផ្លូវនឹងអ្នកមហា      ព្រានាងចរចាប្រាប់ដំណឹង

នាំគ្នាបញ្ឈរក្អែកធ្វើស្ទឹង ឆ្លើយថាស្ដេចពឹងខ្ញុំមកទេ ។
បន្ទន់បទុមស្រីស្ដីសារស័ព្ទ សំដីចំណាប់បេះការកើត
ទូលព្រះបិតាដោយរិះរេ ក្រែងពុំត្រូវទេព្រះបិតា ។
ព្រះអង្គមានបុត្រតែមួយផង គឺខ្ញុំឯងហោងនេះទេណា
ឥឡូវបានកូនមករៀបការ កូននៅឯណាម្ដេចពុំឃើញ ។
ចំណែកស្វាមីគឺប្ដីខ្ញុំ ហួសប្រាំមួយឆ្នាំមិនអញ្ជើញ
លើសដប់ខែទៀតក៏មិនឃើញ មិនទាន់អញ្ជើញមកដល់ឡើយ ។
ប្រហែលបិតាគិតយកខ្ញុំ ផ្សំផ្គុំនឹងគេទេដឹងអើយ
ខ្ញុំសួររកកូនពុំប្រាប់ឡើយ ឱបិតាអើយគិតដូចម្ដេច ។
មហាមេឃបិតានឹងមហាជាល ឮនាងផ្ដាញ់ផ្ដាលដោយពាក្យពេចន៍
គិតថាការនេះមិនសម្រេច តើយើងគិតម្ដេចវិទ្យាមាត្យ ។
បន្ទន់បទុមស្រីមិនយល់ព្រម នឹងលួមគិតការតទៅទៀត
បើដូច្នេះតើគិតវិទ្យាមាត្យ យើងគិតឆ្វះឆ្វៀតដូចម្ដេចវិញ ។
វិទ្យាមាត្យថាអើក្រើមហាមេឃ យើងឃាត់អ្នកពេកពីមុនមិញ
ឥឡូវបើនាងមិនស្រឡាញ់ អញរកកូនណាឲ្យកើតបាន ។
បំណែកខាងអញឥតបង្ខំ នឹងរាយនឹងផ្សំស្រីកល្យាណ
ឲ្យមានប្ដីហើយកែម្ដេចបាន យើងខានបន្ទំទៅក្រើរើយ ។
កាលនោះមហាជាលអសុរីបុត្រ ខឹងញ័ររន្ធត់ពេកជាត្រើយ

សំយ៉ុងកក្រដ្បប់មិនងើបឡើយ    ខ្មាស់អើយសែនខ្មាស់ឥតឧបមា ។
ទើបក្រោកចេញពីទីប្រជុំ    ដោយកើតទុក្ខធំក្នុងកាយា
ស្រែកប្រាប់ប្រកាសពោលពាក្យថា    ចន្ទ័បទុមាយកឲ្យបាន ។
រឿងនេះឈប់ស្ទេះមិនពណ៌នា    សូមថ្លែងចរចាដោយដើមដាន
ពីក្សត្រពីរពង្សទ្រង់យានបាន    ចរចូលក្នុងស្ថានក្រុងយក្សា ។
យាត្រាចូលក្នុងទីរាំងជ័យ    ដោយឥតខ្លាចភ័យយក្សឯណា
ចូលដល់ទៅក្រុងអសុរា    ជាព្រះបិតារបស់ខ្លួន ។
កាលនោះក្សត្រិយ៍ស្រីចន្ទ្រា    ចន្ទ័បទុមាស្រស់ស្រីសួន
ក្រឡេកឃើញប្ដីហើយនឹងប្អូន    ស្រីនួនស្ទុះទៅប្រាំឱប ។
ទើបស្ដេចទ្រង់លើកព្រះហត្ថា    ទាំងពីរហើយណាទ្រង់ក្រសោប
បង់បាត់ស្មារតីដូចគេគ្រប    ប្រាំឱបហើយសោយសោកា ។
ជាទីកំសត់ស្រស់ពន្លក    បងស្ទុះស្ទួនមករកពំនារ
បំណាច់បំណងបងប្រាថ្នា    ឥឡូវជួបគ្នាហើយស្រីពៅ ។
កាលនោះនាងចន្ទ័បទុមស្រី    នឹកព្រះស្វាមីពេកឆោមឆៅ
ក្នុងចិត្តអន្លួលរំជួលក្ដៅ    នឹងយក្សឃោរឃៅពេញត្រៀបត្រា ។
ទើបនាងក្រាបទូលព្រះស្វាមី    ឲ្យប្រញាប់សេចក្ដីសព្វកិច្ចការ
ចំពោះព្រះភក្ត្របិតា    កុំឲ្យទិន្នាដល់នាងឡើយ ។
ពួកយក្សតណ្ដឹងគិតរៀបការ    ខ្ញុំម្ចាស់នេះណានឹងគេហើយ

បិតាប្រកែកថាមិនឲ្យ ខ្លាចក្រែងថ្ងៃក្រោយមានរឿងធំៗ
មហាមេឃអសុភបេះតែមក បេះតែលលកគិតរៀបចំ
ឥឡូវរឿងនេះបែកការធំ កំពុងជុំជុំជំរះគ្នា ៗ
កាលអឺយកាលនោះអង្គក្សត្រថ្ងៃ ឯកាចក្រីមានបេស្តា
ឮព្រះក្សត្រិយ៍ស្ដីចរចា បន្ទូលប្រាប់ថាសព្វសេចក្ដី ៗ
ស្ដេចត្រាស់តម្រាសតបទឹងយក ឥតមានទើសទាក់ដោយសំដី
ថាចំណែកខាងអសុរី ដែលចូលមកស្ដីប្រពន្ធខ្ញុំ ៗ
បិតាប្រកែកថាមិនឲ្យ ចូលមកញយៗគិតរៀបចំ
ចន្ទ៍បទុមនេះប្រពន្ធខ្ញុំ មករៀបចំការជួបស្ដេចបាន ៗ
បេះធ្វើបំពានអាងអំណាច អាងខ្លួនមិនខ្លាចចិត្តសាហ៊ាន
ធ្វើម្ដេចធ្វើទៅឲ្យតែបាន បំពុះបំពានអាងបេស្ដា ៗ
កាលអឺយកាលនោះក្រុងមហាមេឃ ដួងចិត្តក្ដៅពេកក្រេវក្រោធា
ថាយើងអាដែងជាតិមនុស្ស ចិត្តវាមោហាព្រហើនក្រៃ ៗ
វាហ៊ានពោលពាក្យថាឲ្យអញ អានេះវាមិនស្គាល់គេដដែ
អាចោរមនុស្សចិត្តចង្រៃ មុខស្លាប់នឹងដៃអញមិនខាន ៗ
ថាហើយទ្រនាំដែនពសុធា យក្សក្រេវក្រោធាពន់ប្រមាណ
ស្រែកហៅរេហ៍ពលចេញក្រៅស្ថាន ពួកយក្សប៉ុន្មានគិតចម្បាំង ៗ
ពួកយក្សហ៊ឹកហ៊ាក់ច្រើនក្រៃពេក អនន្តអនេករៀបតតាំង

ដោយទឹកឈឺចិត្តដេរដេះខ្ទាំង ប្រណាំងវិទ្ធីព្រះចេស្ដា ។
កាលនោះឯអគ្គព្រះចមចក្រ ជាព្រះរៀមរកអគ្គឯកា
គង់ជិតស្រីចន្ទ័បទុមា កក្ដ្រដូបចន្ទ្រាមូលក្រឡង់ ។
ព្រមទាំងព្រះបាទអនុជា ជាកនិដ្ឋាព្រះចមពង្ស
ប្រថាប់ព្រះទែនទាំងបីអង្គ គង់គាល់វិរុឡ្ហមាត្យពង្សក្សត្រា ។
ទ្រង់ទតព្រះនេត្រឃើញពលយក្ស ច្រើនរាន់គ្សអនេកា
ទើបស្ដេចមានព្រះបន្ទូលថា ហៃកូនទេវ្ហា ទាំងពីរប្រាណ ។
ហេតុនេះយើងគិតធ្វើដូចម្ដេច មហាមេឃអសុរចិត្តក្លាហាន
ប្រមូលពួកពលមីរមូលបាន ពាសពេញក្នុងស្ថានព្រះសេមា ។
ដូចនេះតើកូនគិតដូចម្ដេច កុំឲ្យថោកទាបព្រះចេស្ដា
កុំឲ្យថោកទាបដល់សេមា ថោកដល់មាតាបិតាផង ។
ដូចនេះបិតាប្រគល់ឲ្យ តទៅខាងក្រោយសោយរាជ្យផ្គង
ជំនួសបិតាអញឯងហោង ស្នងត្រង់នគរលើកនឯង ។
កូនប្អូនជុំពុកឲ្យអំណាច ឡើងធ្វើឧបរាជ្យប្រាកដស្ដែង
ប្រគល់រហ៍ពលទ័ពកន្ទ្វង ស្រេចទឹងកូនឯងទាំងទេវ្ហា ។
ចន្ទ័បទុមាជាបុត្រី តាំងទីមហេសីអគ្គឯកា
ជាធំលើសអស់ស្នំស្រីស្គារ ក្នុងព្រះសេមាពេជ្របុរី ។
ឥឡូវហេតុនេះកើតចម្បាំង ប្រណាំងដណ្ដើមបទុមស្រី

តើគិតដូចម្ដេចបុត្រពិសី ខ្លាស់អសុរីក្រុងមហាមេឃ ។
កាលអើយកាលនោះអង្គឯកា ព្រះបិតាព្រួយខ្លាំងពេក
ដោយឃើញពលយក្សច្រើនអនេក ឥតមានប្រកែកដល់តិចឡើយ ។
ប្រាប់អនុជាឲ្យរៀបពល ប្រញាប់ខ្វាយខ្វល់មកដល់ហើយ
ចម្បាំងពេលនេះពុំលែងឡើយ ពលពាលមុខក្រោយពេញត្រៀបត្រា
រៀបស្រេចចូលទូលអង្គចមក្សត្រ បពិត្របក្រពត្រចមដេជ្ជា
បំណែកខាងពួកពលសេនា រួចស្រេចហើយណាព្រះរៀមថ្លៃ ។
ព្រះបាទឯកាចមចក្រ ព្រះអនុជស្ដីត្រេកអរក្រៃ
ចុះចាកប្រាសាទរំពេចខ្ញី បង្គាប់សេនីយ៍ទាំងសេនា ។
ឲ្យរៀបប្រុងប្រៀបរៀបគ្រប់ប្រាណ សេនាប៉ុន្មានសង្គ្រាមជ័យ
យើងលើកទៅតទឹងអសុរ ឲ្យដឹងដេដដៃក្នុងគ្រាទឹង ។
កាលនោះមហាមេឃអង្គអសុរី គ្រាំក្រោធពេកក្រៃដោយកំហឹង
មហាផាលអសុរាក៏ក្រោធខឹង គិតថាពេលនឹងឲ្យអស់ឫទ្ធិ ។
បើសិនអញចាញ់កាមនុស្ស ស្លាប់ទៅកាលណាអញលែងគិត
រស់នៅធ្វើអ្វីខ្មាស់រាពិត ឲ្យអស់ជីវិតល្អជាជាង ។
មហាមេឃអសុរីថុលធេវខ្លាំង ប្រកាសចម្បាំងព្វស្បូរសៀង
មហាផាលបុត្រាក៏ក្អេងក្អាង ព្វបង្រាស់ដល់នាងចន្ទបទុម ។
កាលអើយកាលនោះវរក្សត្រិយ៍ ព្វពាក្យអសុរីពុំគួរសម

ទុកជាទុក្ខមុខក្រៀមក្រំ បារម្ភអំពីសង្គ្រាមជ័យ ៗ
ក្រែងទប់ទល់រិទ្ធិយក្សពុំបាន អសុរាខ្លាហានឥតឧបម័យ
ក្រែងព្រះបរមក្សត្រិយ៍ថយតេជដៃ ក្រុងអសុរីយកនាងបាន ៗ
តាំងពីក្សត្រាយាងមកដល់ ទីស្ថានមណ្ឌលព្រះរាជស្ថាន
ពុំដែលបានជុំសុខសម្រាន្ត ជាមួយកល្យាណទឹមទួនស្រី ៗ
កើតកោលាហលខ្វល់វិកវរ ក្នុងព្រះនគររាជបុរី
ពុំបានរួមស្ថានទឹងមហេសី ដោយព្រះបក្រិមាះភ័យធំ ៗ
ព្រះបាទឯកាចក្កវិទ្ធិ ព្រះទ័យទ្រង់គិតក្តីបារម្ភ
ស្រុកកើតសឹកសាមសង្គ្រាមធំ ប្រជុំគិតតែគ្រឿងចម្បាំង ៗ
កាលនោះសម្តេចអនុជា លើកពលយោធាចេញតតាំង
ទឹងក្រុងអសុររិទ្ធិខ្លាំង ថ្វីដោយកម្លាំងរិទ្ធិពលប្រាណ ៗ
ក្រុងយក្សថ្វីងជាគំនរភ្លើង ឆេវឆាបឆេះឡើងក្នុងរាជស្ថាន
ព្រះបាទឯកាក្សត្រិយ៍ថ្កើងថ្កាន យកកន្សែងបានបក់ឡើងខ្ទី ៗ
កើតជាទឹកភ្លៀងលត់ភ្លើងយក្ស ត្រជាក់សាយសព្វកតពផែនដី
គ្មានក្តៅផល់ពួកពលសេនីយ៍ ទឹងពីរក្សត្រថ្វីដល់តិចឡើយ ៗ
យក្សថ្វីងពពកធ្វើឲ្យលិត មេឃខ្មៅជុំជិតសព្វទិសហើយ
ចូលត្រកងបស្ត្រីត្រាណត្រើយ យកបានមកហើយពីរាជស្ថាន ៗ
ពហោះសំដៅទៅនគរ ឈ្មោះកោះគិរីរាជក្រើងថ្កាន

ព្រះបាទឯកាចមក្សត្រក្បួន　　ចាប់កន្សែងបានបក់ឡើងខ្ចី ៗ
កើតជាពាយោបក់ផាយផាត់　　រសាត់ពពកអន្ទអប្រិយ៍
ទ្រង់ទតព្រះនេតឃើញអសុរី　　ពបទុមស្រីហោះលឿនក្រៃ ៗ
ស្តេចលើកព្រះហស្ថខាងស្តាំឡើង　　បន្ទុលប្រាប់ព្រះអនុជថ្លៃ
ប្អូនប្រុសមើលនយក្សចង្រៃ　　ពបទុមស្រីហោះទៅហើយ ៗ
ទើបព្រះអនុជមានបុណ្យច្រើន　　ចាប់យកខ្សែឡើងគ្រវែងផ្ញើយ
ដេញចងក្រុងយក្សជាប់ពីក្រោយ　　ទាញបានមកហើយចំពោះភ័ក្ត្រ ៗ
ចងទាំងវេហ៍ពលយក្សប៉ុន្មាន　　រូបរិតអង្គប្រាណទាញកន្ត្រាក់
ដម្បងកាយឯងឥតក្រែងយក្ស　　ភិតភ័យព្រឺញាក់រាក់ស្មារតី ៗ
យក្សស្រែកអង្វរក្សត្រទ្រហា　　បពិត្រដេជ្ញាចមចក្រី
ព្រះអង្គជាម្ចាស់លើសិរសី　　សូមព្រះនរបតីទុកជីពជន្ម ៗ
សូមចុះសូមចាញ់ព្រះបារមី　　ថ្វាយទឹកថ្វាយដីស្រុកដម្បូន
ប្រទេសនិគមឃុំខេត្តខណ្ឌ　　ក្រុងធំសោភ័ណកោះគិរី ៗ
មហាមេឃបិតាអង្វរក្សត្រ　　ទាំងពីរចក្កតេលុងដូលី
ឯអសុរីបុត្រផុតជីវី　　ក្ស័យនៅក្នុងទីនោះឯងណា ៗ
ខ្សែពីរសង្ខេបជាបែបខ្វី　　តទៅខ្សែបីស្តីអស្ចារ្យ
ពីអសុរីបុត្រផុតសំខារ　　កើតឡើងកាលណាតបទៀតវិញ ៗ

ពលឯក ទីពីរ ចប់

មានតខ្សែ៣ទៀត

រោងពុម្ពកុមារពាណិជ្ជ

លេខ ៦ មហាវិថីឡៀនស៊ីស៊ុរគ្គិ

ភ្នំពេញ

តំលៃ ១០រៀល